**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីសម្រេចបន្តអាណត្តិអាជ្ញាប័ណ្ណរួមលេខ ០៦២ ឯអ
## សម្រាប់លោក កែប បូរី
## អាជ្ញាធរអគ្គិសនីកម្ពុជា

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-យោងឯកសារអាជ្ញាប័ណ្ណលេខ០៦១ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានចេញឱ្យលោក **កែប បូរី** នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៣

-យោងពាក្យស្នើសុំបន្តអាណត្តិអាជ្ញាប័ណ្ណរបស់លោក **កែប បូរី** ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០៥

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៥ ដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៥

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី៦១ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៦

## សម្រេច

### ប្រការ១

ដោយលោក **កែប បូរី** បានធ្វើការកែលម្អមធ្យោបាយធ្វើសេវាកម្មអគ្គិសនីរបស់ខ្លួនបានតិចតួច ហើយតម្រូវឱ្យលោក **កែប បូរី** ធ្វើការកែលម្អច្រើនបន្ថែមទៀត នៅឆ្នាំបន្តបន្ទាប់ ដើម្បីឱ្យស្របតាមល័ក្ខខ័ណ្ឌទូទៅនៃស្តង់ដាបច្ចេកទេសក្នុងព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចកែសម្រួលអាជ្ញាប័ណ្ណរួមលេខ០៦២ ឯអ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៣ ដែលបានផ្តល់ជូនលោក **កែប បូរី** ដើម្បីឱ្យលោកបន្តធ្វើសេវាកម្មផលិត និងចែកចាយអគ្គិសនីនៅទីប្រជុំជនផ្សារព្រែកក្តាមខាងកើត ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល ដោយបន្តផ្តល់អាណត្តិអាជ្ញាប័ណ្ណសាកល្បងចំនួន **០២(ពីរ) ឆ្នាំ** បន្តទៀត ។

### ប្រការ២

អាណត្តិអាជ្ញាប័ណ្ណសាកល្បងនេះមានរយៈពេល ០២(ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៥ និងអាចស្នើសុំបន្តទៀត ឬស្នើសុំកែសម្រួល លើកលែងតែត្រូវដកហូត ដោយអនុលោមតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ។

**ប្រការ៣**

សេចក្ដីសម្រេចនេះ ត្រូវក្លាយជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០៦២ ឯអ ។

**ប្រការ៤**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ០៦២ ឯអ ត្រូវស្ថិត នៅជាធរមានដដែល ។

**ប្រការ៥**

សេចក្ដីសម្រេចនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្ដីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែង ដូចតម្កល់ទុកឯកសារអាជ្ញាប័ណ្ណលេខ ០៦២ ឯអ ពីលើកមុន ដើម្បីឱ្យឯកសារ អាជ្ញាប័ណ្ណលេខ ០៦២ ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មី ស្រប តាមសេចក្ដីសម្រេចនេះ ។

ភ្នំពេញ, ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៦

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

## ឧបសម្ព័ន្ធទី២
## មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អ្នកកាន់អាជ្ញាប័ណ្ណ

**ក. មធ្យោបាយផលិតកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ**

**រោងម៉ាស៊ីន**

១- ទីតាំងម៉ាស៊ីនភ្លើងរបស់អ្នកកាន់អាជ្ញាប័ណ្ណ ស្ថិតក្នុងភូមិព្រែកក្តាម១ ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល។

**លក្ខណៈទូទៅនៃម៉ាស៊ីន**

អ្នកកាន់អាជ្ញាប័ណ្ណ មានម៉ាស៊ីនភ្លើងចំនួន ០២គ្រឿង ដែលមានអានុភាពតំឡើងសរុប 120 kVA គឺ

-ម៉ាស៊ីនលេខ១ អានុភាព 70 kVA

-ម៉ាស៊ីនលេខ២ អានុភាព 50 kVA

២- ម៉ាស៊ីនភ្លើងខាងលើ ប្រើប្រាស់ប្រេងម៉ាស៊ូត ។

លក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះមានខ្លឹមសារដូចអាជ្ញាប័ណ្ណលេខ០១៥.ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២។ ប្រសិនបើចង់ពិនិត្យមើលខ្លឹមសារ សូមពិនិត្យមើលផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។